01204541

002/19-09-2007-ECCC/TC
E1/388

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 02 / 2016
ម៉ោង (Time/Heure) : 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ អង្គារ ទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦

**សវនាការលើភស្តុតាង - ថ្ងៃ ៣៦៩**

រៀបចំដោយ៖ **ឯម ហ៊ីយ** និង Roger PHILLIPS

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc Lavergne, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោក ឯម ហ៊ីយ , លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicolas KOUMJIAN, លោក ស្រ៊ា រតនៈ,កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ, Ms. Soumeya MEDJEBEUR, Ms. SENG Socheata. |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី , លោកស្រី ស៊ីន សុវ៉ន , លោក ហុង គីមសួន, លោក វ៉េន ពៅ,លោកស្រី ទ្រី ស្រ៊ីនណា, លោកស្រី ជេត វណ្ណលី, លោកស្រី Eleonor FERNANDEZ. |
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ លោក អ៊ីសា ឧស្មាន (2-TCE-95), លោកស្រី Julie BARDECHE មន្ត្រីច្បាប់មកពីការិយាល័យសហចៅក្រមស៊ើបអង្កេត |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក កែវ រ៉ាត , ,លោក ឡូញ ង៉ែត, លោកស្រី សម មករា, លោក មៀច សុវណ្ណា,កញ្ញា Hannah KIM |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៧ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៣ | បញ្ចប់ម៉ោង៖ ១០.៣៤ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤១ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២០ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៨ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៨ | ០៩.១០ |
| សេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការព្រួយបារម្ភដែលបានលើកឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត | អង្គជំនុំជម្រះ | ០៩.១៩ | ០៩.២៥ |
| ការស្តាប់សក្ខីកម្មអ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95) | អង្គជំនុំជម្រះ | ០៩.១២<br>០៩.២៥<br>១០.៣៤ | ០៩.១៩<br>១០.១២<br>១០.៥៣ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា | ១០.៥៤ | ១១.៣៣ |
| | | ១៣.៣២ | ១៤.៤១ |
| | | ១៥.០១ | ១៦.០៧ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងបានជំរាបជូនដល់ភាគី និងសាធារណជនថា នៅថ្ងៃនេះ ចៅក្រម យូរ ឧត្តរា អវត្តមាន និងអាចរហូតដល់ថ្ងៃស្អែកដោយមានបញ្ហាសុខភាព ហើយជំនួសដោយចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងជាតិ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការ។

**សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងការព្រួយបារម្ភដែលបានលើកឡើងដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេត**

ចំពោះទម្រង់សំណួរដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ កាលពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥ សម្រាប់ការសួរអ្នកជំនាញ អ៊ីសា ឧស្មាន អង្គជំនុំជម្រះបានស្នើឱ្យភាគីធ្វើសារណាផ្ទាល់មាត់ អំពីវិធានការដែលបានស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។អង្គជំនុំជម្រះបានចេញនូវអនុស្សរណៈរបស់ខ្លួនអំពីទម្រង់នៃការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ ឯកសារ (E367/6) ជូនទៅដល់ភាគីទាំងអស់ ។ គ្រប់ភាគីត្រូវបានធ្វើការណែនាំផងដែរឱ្យដាក់បញ្ជីឯកសាររបស់ខ្លួនដែលត្រូវប្រើប្រាស់សម្រាប់សួរអ្នកជំនាញ។ អង្គជំនុំជម្រះបានកត់សម្គាល់ចំពោះវត្តមានមន្ត្រីច្បាប់តំណាងឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត។ មានការហាមឃាត់មិនឱ្យភាគីប្រើប្រាស់ឯកសារបកប្រែនៅក្នុងក្រុមរបស់ខ្លួនចំពោះឯកសារដែលមានតែមួយភាសា ប៉ុន្តែអនុញ្ញាតឱ្យសមាជិកក្រុមរបស់ខ្លួនអានឯកសារដើម ហេតុដូច្នេះហើយអ្នកបកប្រែ អាចធ្វើការបកប្រែប្រដេញបាន។ ជាចុងក្រោយ អង្គជំនុំជម្រះ បានធ្វើការរំលឹកដល់អ្នកជំនាញថា ខ្លួននឹងធ្វើការឆ្លើយតបចំពោះការកំណត់អំពីភាពពាក់ព័ន្ធនៃសំណួរ និងភ័ស្តុតាង ។

ការស្តាប់សក្ខីកម្មអ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95)
អង្គជំនុំជម្រះ សាលាដំបូងរាជអាជ្ញា បានតាំងសំណួរទៅកាន់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95)

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E367/1 | | 01149658-01149660; 01149656-01149657 | [Corrected 1] Letter from ICIJ concerning the Expert Testimony of OCIJ analyst Osman YSA | P | 01149659 | 01149657 | - |
| E367/6 | | 01200781-01200784; 01200775-01200777; 01200778-01200780 | [Corrected 1] Trial Chamber Memorandum entitled: Modalities of Testimony for 2-TCE-95 | P | 01200781 | 01200775 | 01200778 |
| E215 | | 00822610-00822625; 00821265-00821274; 00824115-00824125 | Decision on Assignment of Experts | P | 00822623 | 00821272 | 00824123 |
| E3/1593 | | 00637356-00638099; 01149978-01150245; 00638722-00639444 | [Corrected 1] Book by Ben Kiernan entitled "The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge, 1975-79" | P | 00637755 | 01150136 01150137 | 00639022 00639251 00639049 |
| E3/178 | D00707 | 00017147-00017160; 00183363-00183373; 00296158-00296167 | Minutes of the Meeting on Social Affairs and Health on 10/6/76 | P | 00275588 | 00342709 | 00623305 |
| E3/2653 | D196.2 | 00904196-00904430; 00219050-00219245; 00943973-00943985 | YSA Osman, "Rebellion: Survivor's Stories from the Village", DC-Cam, 2006 | P | - | 00219193 00219210 | 00904414 00904408 |
| E367/4.1.7 | | 01199595-01199598 | Attachment 7: Michael Vickery, Comments on | P | - | 01199596 | - |

01204545



| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | Cham Population Figures', Critical Asian Studies, Vol. 22, No. 1, January - March 1990 | | | | |
| E367/4.1.4 | | 01199557-01199558 | Attachment 4: YSA Osman, 'How many Cham killed important genocide evidence', Phnom Penh Post, 10 March 2006 | P | - | 01199558 | - |
| E3/1822 | | 00338995-00339006; 00078437-00078604; 00758327-00758335 | Book by YSA Osman entitled: "OUKOUBAH – Justice for the Cham Muslins under the Democratic Kampuchea regime" | P | - | 00078450 00078573 00078568 00078569 | 00758327 00758331-00758332 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.២៥)
- នៅពេលមានសួរសំណួរទៅកាន់អ្នកជំនាញ 2-TCE- 95 ស្នើឱ្យភាគីធ្វើសេចក្តីសម្រេចផ្ទាល់មាត់អំពីវិធានការដែលបានស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះការដាក់បញ្ជីឯកសាររបស់ខ្លួនដើម្បីប្រើប្រាស់ និងហាមឃាត់មិនឱ្យប្រើប្រាស់ឯកសារបកប្រែនៅក្នុងក្រុមរបស់ខ្លួនចំពោះឯកសារដែលមានតែមួយភាសា (៩.២៥)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃពុធទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៦

ក្រឡាប[illegible]បញ្ជី

ឯម ហ៊ី[illegible] Ro[illegible] PHILLIPS